ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ០៥៩៤ ព.ណ.ចបព

ថ្ងៃ៣ ៩កើត ខែ មាឃ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩

# សេចក្ដីជូនដំណឹង

## ស្ដីពីការបើកវគ្គបណ្ដុះបណ្ដាលអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម (ជំនាន់ទី២)

ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូនដល់សាធារណៈជនទាំងអស់មេត្តាជ្រាបថា ក្រសួងពាណិជ្ជកម្មនឹងរៀបចំវគ្គបណ្ដុះបណ្ដាលអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម (ជំនាន់ទី២) ចំនួនសរុប ៧០នាក់ ។

វគ្គបណ្ដុះបណ្ដាលនេះ រៀបចំឡើងក្នុងគោលបំណងគ្រប់គ្រង និងពង្រឹងសមត្ថភាពអ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុន សហគ្រាស បង្កើនប្រសិទ្ធភាពនៃការអនុវត្តន៍ច្បាប់ ប្រកាស និងសេចក្ដីជូនដំណឹងពាក់ព័ន្ធការចុះបញ្ជីពាណិជ្ជកម្ម និងគាំទ្រដល់ការផ្ដល់សេវាចុះបញ្ជីពាណិជ្ជកម្មឱ្យកាន់តែប្រសើរឡើង ដូចបានកំណត់ក្នុងប្រកាសលេខ ២៥៨ ព.ណ ចបព.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីការទទួលស្គាល់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ឬឯកសារនាំចេញ-នាំចូល នៅក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

### ១. នីតិវិធីនៃការដាក់ពាក្យ

អ្នកដែលមានបំណងចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលខាងលើ ត្រូវដាក់ពាក្យស្នើសុំតាមរយៈសារអេឡិចត្រូនិក business.reg.info@gmail.com ចាប់ពីម៉ោង ៨:០០ ព្រឹក ថ្ងៃសុក្រ ១០រោច ខែ មាឃ ឆ្នាំច សំរឹទ្ធិស័កព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៩ តទៅ។ ក្រសួងពាណិជ្ជកម្ម នឹងបញ្ចប់ការទទួលពាក្យស្នើសុំត្រឹមចំនួន ៧០ នាក់ដំបូងដែលបានផ្ញើសារអេឡិកត្រូនិក មកតាមពេលវេលាកំណត់ខាងលើ។ អ្នកស្នើសុំ ត្រូវទាញពាក្យស្នើសុំពីគេហទំព័រក្រសួងពាណិជ្ជកម្ម https://www.moc.gov.kh/Portals/0/Docs/OfficialDocs/Application-20190211143703873.pdf និងត្រូវបំពេញពាក្យស្នើសុំរួចភ្ជាប់មកជាមួយឯកសារតម្រូវតាមប្រកាស ២៥៨ ព.ណ ចបព.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ជាទំរង់ PDF រួចផ្ញើមកសារអេឡិចត្រូនិក។ ពាក្យស្នើសុំនឹងត្រូវចាត់ទុកថាបានទទួល តាមរយៈសារអេឡិកត្រូនិក ដែលបានផ្ញើមកតាមលំដាប់លំដោយតាមលេខរៀងពេវេលាម៉ោងដែលបានស្នើសុំរហូតដល់គ្រប់ចំនួន។ បេក្ខជនដែលបានផ្ញើសារអេឡិចត្រូនិច៧០នាក់ដំបូង ត្រូវយកពាក្យស្នើសុំ និងឯកសារតម្រូវច្បាប់ដើមមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មក្រោយពីបានទទួលដំណឹងពីក្រសួងពាណិជ្ជកម្ម។ ក្រសួងពាណិជ្ជកម្ម នឹងធ្វើការឆ្លើយឆ្លងជាមួយអ្នកស្នើសុំតាមរយៈសារអេឡិកត្រូនិក។

### ២. បញ្ជីឈ្មោះបេក្ខជនដែលត្រូវចូលរៀនវគ្គបណ្ដុះបណ្ដាលជំនាន់ទី២

ក្រសួងពាណិជ្ជកម្មនឹងចេញបញ្ជីឈ្មោះបេក្ខជនដែលត្រូវចូលរៀនវគ្គបណ្ដុះបណ្ដាលជំនាន់ទី២តាមលក្ខខណ្ឌដូចខាងក្រោម៖

- បេក្ខជនត្រូវស្ថិតនៅក្នុងលំដាប់លេខរៀងសារអេឡិកត្រូនិកដែលបានផ្ញើមក៧០នាក់ដំបូង
- បេក្ខជនត្រូវបំពេញពាក្យស្នើសុំត្រឹមត្រូវ និងភ្ជាប់ឯកសារតម្រូវគ្រប់គ្រាន់
- ចំពោះបេក្ខជនដែលមិនបានបំពេញលក្ខខណ្ឌចំនុចទីពីរខាងលើ នឹងមិនត្រូវបានជ្រើសរើសក្នុងបញ្ជីឈ្មោះបេក្ខជនដែលត្រូវចូលរៀនវគ្គបណ្ដុះបណ្ដាលជំនាន់ទី២ទេ ហើយបេក្ខជនដែលមានលំដាប់លេខរៀងបន្ទាប់ពីលេខ៧០ឡើងទៅ នឹងត្រូវជ្រើសរើសជំនួស។

*សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់៖*
*092 888 326 / 078 555 959 ដែលមាន Extension លេខ 0 ឬ 3*